# ដំណាំត្រប់

## ១. ការបណ្ដុះកូន


រៀបចំដីដាក់កន្ទោងស្លឹក រឺថាស់បណ្ដុះកូន


១កន្ទោងដាក់១គ្រាប់ រឺ ១ប្រលោះថាសបណ្ដុះ១គ្រាប់



- ធ្វើដំបូលគ្របពីស្លឹកដូង រឺ សំណាញ់កាត់ពន្លឺ
- រើដំបូលចេញ ៣ថ្ងៃមុនដាំដើម្បីអោយកូនរឹងមាំល្អ
- គ្របចំបើងពីលើថាសបណ្ដុះកូន រឺ កន្ទោងស្លឹក
- បន្ទាប់ពីសាបគ្រាប់ ២-៣ថ្ងៃយើងអាចដកចំបើងចេញ
- ដករំលោះកូនបន្ទាប់ពីកូនដុះបាន៧ថ្ងៃគឺ១កន្ទោង ទុកតែ១ដើមប៉ុណ្ណោះ។

## ២. ការរៀបចំដី

- ភ្ជួរ ២-៣ដង ក្នុងជំរៅពី ២៥-៣០ ស.ម ហើយរាស់បំបែកដីអោយរាបស្មើរួចហាលដីអោយស្ងួត។

## ៣. ការលើករង

- **បណ្ដោយរង:** មិនត្រូវបានកំណត់ទេ អាស្រ័យទៅតាមលទ្ធភាពផ្ទៃដីដែលមាន
- **ទទឹងរង:** មិនត្រូវលើសពី ១ -១,២ម ឡើយ
- **ចន្លោះរង:** ចន្លោះពីរងមួយទៅរងមួយពី ០,៥ ម
- **កំពស់រង:**
  - រដូវប្រាំង: កំពស់ ២០ ស.ម ដោយមានកំពែង ដើម្បីកុំអោយទឹកហូរចេញ
  - រដូវវស្សា: កំពស់ ៣០ស.ម រាងជាខ្នងអណ្ដើក។ ចន្លោះពីរងមួយទៅរងមួយមានចង្អូរទឹក

## ៤. ការដាំកូន

- គ្របរងដោយ ចំបើង(កំរាស់យ៉ាងតិច៥សង់ទីម៉ែត្រ)រឺផ្លាស់ស្ទិកគ្របរង ដើម្បីការពារស្មៅចង្រៃនិងរក្សាសំណើមដី
- មុនដកកូនទៅដាំត្រូវបន្ថយការស្រោចទឹក (ស្រោចមិនជាកពេក) ២-៣ថ្ងៃ ដើម្បីអោយកូនមានភាពរឹងមាំ
- មុនយកកូនទៅដាំប្រមាណ៣ថ្ងៃត្រូវបន្ថយការស្រោចទឹក (ស្រោចមិនអោយជោគពេក) ដើម្បីអោយដើមរឹងមាំតែមុនដកដាំត្រូវស្រោចទឹកអោយជោគសិននៅពេលព្រឹក ហើយដាំនៅពេលរសៀល ។
- កូនអាយុ ២០-២៥ ថ្ងៃ ឬ កូនមានសន្លឹកពី ៤-៥ អាចដាំបាន
- ចន្លោះជួរ ៦០ស.ម និង ចន្លោះគុម្ព ៥០ស.ម និង **ដាំ១ រណ្តៅ តែ ១ដើម** (សូមមើលរូប)




## ៥. ការប្រើប្រាស់ជី

សំរាប់ពូជបន្លែទំនើបមានការប្រើប្រាស់ជីគីមី និងជីធម្មជាតិច្រើនបើធៀប និង ពូជបន្លែក្នុងស្រុក។ ជីដែលបានដាក់មានប្រសិទ្ធិភាពពេលណាយើងស្រោចទឹកបានគ្រប់គ្រាន់។ ទឹកមានតួនាទីជាអ្នកនាំជីដែលបានដាក់អោយទៅដល់ឬសដំណាំ ហើយធ្វើអោយដំណាំលូតលាស់បានល្អ ។

**របៀបដាក់ជីទ្រាប់បាត:**

- ប្រភេទទី១ យើងត្រូវយកជីគីមី និងជីលាមកសត្វមកពង្រាយលើរង ទើបកាប់ច្របល់ជីទាំងនេះជាមួយដីសើ១ ទើបយើងធ្វើរណ្តៅដាក់ដាំកូន។
- ប្រភេទទី២ យើងអាចដាក់ជីនៅក្នុងរណ្តៅ ហើយលាយច្របល់ជាមួយដីបន្ទាប់មកទើបដាំកូនចំងាយប្រមាណ ៥ ស.ម ពីជីដែលច្របល់នោះ។

- **របៀបដាក់ជីបំប៉ន:** យើងត្រូវជីកកប់ជីដែលត្រូវដាក់នៅសងខាងរណ្តៅ រឺនៅចន្លោះគុម្ព។ មិនត្រូវដាក់ជីជាប់នឹងគល់បន្លែទេ របៀបដាក់ជីដូចជា:
  - ២ អាទិត្យបន្ទាប់ពីដាំ ត្រូវដាក់ជី ចំងាយប្រមាណ ៥ស.ម ពីគល់បន្លែ
  - ៤ -៥ អាទិត្យបន្ទាប់ពីដាំ ត្រូវដាក់ជី ចំងាយប្រមាណ ១០ស.ម ពីគល់បន្លែ
  - លើសពី៥អាទិត្យបន្ទាប់ពីដាំត្រូវដាក់ជី ចំងាយប្រមាណ១៥ស.ម ពីគល់បន្លែ

**របៀបដាក់ជីបំប៉ន**

កន្លែងដាក់ជីបំប៉នអាស្រ័យទៅតាមអាយុកាលដំណាំ។

យើងត្រូវឆូត រឺ បុករណ្ដៅដាក់ជីហើយចូកដីលុបវិញ




កូនដំណាំនៅតូចមានឫសខ្លី

ដូច្នេះកន្លែងដាក់ជីត្រូវនៅក្បែរគល់

កូនដំណាំធំមានឫសវែង

ដូច្នេះកន្លែងដាក់ជីត្រូវនៅឆ្ងាយពីគល់

- **បរិមាណជីដែលត្រូវដាក់**

| | |
|---|---|
| ដាក់ជីទ្រាប់បាត | **ជី កែង** ១៣ក្រាម (១ស្លាបព្រាបាយ)/ដើម **ជីលាមកសត្វ** 0.៥គីឡូក្រាម/ដើម |
| **ការដាំកូន** | |
| ១ អាទិត្យបន្ទាប់ពីដាំ | |
| ២ អាទិត្យបន្ទាប់ពីដាំ | **ជីអ៊ុយរ៉េ** ២.៥ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម |
| ៣ អាទិត្យបន្ទាប់ពីដាំ | |
| ៤ អាទិត្យបន្ទាប់ពីដាំ | **ជី កែង** ២.៥ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម |
| ៥ អាទិត្យបន្ទាប់ពីដាំ | |
| ៦ អាទិត្យបន្ទាប់ពីដាំ | **ជី ប៉ូតាស្យូម** ១.៩ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម |
| ៧ អាទិត្យបន្ទាប់ពីដាំ | |
| ៨ អាទិត្យបន្ទាប់ពីដាំ | **ជី កែង** ២.៥ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម |
| ៩ អាទិត្យបន្ទាប់ពីដាំ | |
| ១០អាទិត្យបន្ទាប់ពីដាំ | |
| ១១អាទិត្យបន្ទាប់ពីដាំ | **ជី កែង** ២.៥ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម |
| ១២អាទិត្យបន្ទាប់ពីដាំ | |
| ១៣អាទិត្យបន្ទាប់ពីដាំ | |
| ១៤អាទិត្យបន្ទាប់ពីដាំ | **ជី កែង** ២.៥ ក្រាម (១ចុងស្លាបព្រាបាយ)/គុម្ព |
| ១៥អាទិត្យបន្ទាប់ពីដាំ | |
| ១៦អាទិត្យបន្ទាប់ពីដាំ | |
| ១៧អាទិត្យបន្ទាប់ពីដាំ | បញ្ចប់ការប្រមូលផល |

## ៦. ការថែទាំ

- កាត់មែកក្ទៀង រឺ ខ្នែងខ្នែកខាងក្រោមចេញ ដើម្បីកុំអោយផ្លែទាបជាប់នឹងដី
- ១០ថ្ងៃក្រោយដាំ ត្រូវដោតទំរ (កូនឈើ)ទប់កុំអោយដើមដួលនៅពេលមានផ្លែច្រើន
- ត្រូវកាត់ស្លឹកចាស់ៗផ្នែកខាងក្រោមចេញ  ដើម្បីអោយពន្លឺ និងខ្យល់ចូលគ្រប់គ្រាន់



**ដើមត្រូវបានកាត់ខ្នែងផ្នែកខាងក្រោមចេញដើម្បីអោយខ្យល់ចេញចូលបានល្អ**





ដើមត្រប់បេះមិនបានរយៈពេលវែងដោយសាដើមត្រប់មិនបានកាត់ខ្នែងផ្នែកខាងក្រោមចេញ  និងមិនបានដោតទ្រើង

## ៧. ការប្រមូលផល

- អាចប្រមូលផលបាន ពី ៥៥-៨០ថ្ងៃបន្ទាប់ពីដាំ គឺអាស្រ័យនឹងប្រភេទពូជ
- ត្រូវប្រើកាំបិត រឺ កន្រ្តៃដើម្បីកាត់ផ្លែមិនត្រូវប្រលេះផ្លែនឹងដៃទេ វាអាចធ្វើអោយបាក់មែកបាន។





